**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

សុន្ទរកថា

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំស្តីពីដំណើរឆ្ពោះទៅអភិវឌ្ឍគោលនយោបាយសិក្សាពេញមួយជីវិត
ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ

-ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ

-លោក លោកស្រី សមាជិក សមាជិកាទាំងអស់ជាទីមេត្រី !

តាងនាមក្រសួងអប់រំ យុវជន និងកីឡា និងតាងនាមខ្ញុំផ្ទាល់ ខ្ញុំមានមនោសញ្ចេតនារីករាយដោយបានចូលរួមជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំ ស្តីពីដំណើរឆ្ពោះទៅអភិវឌ្ឍគោលនយោបាយសិក្សាពេញមួយជីវិត ដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ SEAMEO CELLL, អង្គការ UNESCO ភ្នំពេញ និងអង្គការ DVV International នាពេលនេះ និងសូមស្វាគមន៍ដ៏ជ្រាលជ្រៅចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ លោក លោកស្រីតំណាងក្រសួងពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសមាជិក សមាជិកាទាំងអស់នៃអង្គពិធី។

ទន្ទឹមនឹងនេះខ្ញុំសូមសរសើរដោយស្មោះចំពោះគណៈកម្មការរៀបកិច្ចប្រជុំ និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ SEAMEO CELLL ដែលបានជួយឧបត្ថម្ភថវិកា និងបច្ចេកទេសគាំទ្រកិច្ចប្រជុំនាថ្ងៃនេះ។

**អង្គពិធីជាទីមេត្រី !**

រាជរដ្ឋាភិបាលបានកំណត់ថា ការអប់រំជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាពជាមួយចក្ខុវិស័យក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានប្រាក់

ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០។

ឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងអប់រំ យុវជន និងកីឡាដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើផ្នែកអភិវឌ្ឍធនធានមនុស្ស ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ផ្អែកលើបរិការណ៍ជាតិ និងអន្តរជាតិ ដូចជា ៖

-រៀបចំការងារអប់រំ យុវជន និងកីឡា ជាអនុវិស័យចំនួន៧

-ផ្តល់ការអប់រំសម្បូរបែបឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមមុខសញ្ញារៀនសូត្រ

-រៀបចំឱ្យមានគន្លងអាជីពសម្រាប់គ្រូបង្រៀន និងមន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់

-កែទម្រង់វិស័យអប់រំ ១៥ ចំណុចដោយផ្តោតលើសសរស្តម្ភទាំង៥ក្នុងការលើកកម្ពស់គុណភាពអប់រំ

-បន្សុីគ្នារវាងក្របខណ្ឌការងារនិងពេលវេលា តាមរយៈការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងអង្គវិបស្សនាអប់រំ

-ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្តកម្មវិធី សកម្មភាព សូចនាករនិងចំណុចដៅ ព្រមទាំងផែនការហិរញ្ញប្បទាន សម្រាប់ ២០១៦-២០២០

-ធ្វើការពង្រឹងបន្ថែមនូវប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃតាមអនុវិស័យនីមួយៗ។

## **អង្គពិធីជាទីមេត្រី** !

ក្នុងឱកាសដែលប្រទេសជាតិយើង កំពុងតែទទួលនូវផលចំណេញពីសុខសន្តិភាព និងស្ថិរភាពនយោបាយ ការសិក្សាជាច្រើនបានបញ្ជាក់ចំពោះការកើនឡើងពីតម្រូវការនូវចំណេះដឹង ចំណេះធ្វើ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ជំរុញសេដ្ឋកិច្ចក្នុងរយៈពេលខ្លី រយៈពេលវែង ក្នុងនោះតម្រូវការចំណេះដឹង និងជំនាញរបស់បុគ្គលម្នាក់ៗ មិនថាកុមារ យុវជន ជនពេញវ័យ ឬមនុស្សចាស់ ទទួលបានការសិក្សាទាំងអប់រំក្នុងប្រព័ន្ធ អប់រំក្រៅប្រព័ន្ធ និងអប់រំមិនផ្លូវការ ធ្វើឱ្យពួកគេមានលទ្ធភាពកាន់តែច្រើនក្នុងផ្លាស់ប្តូរទៅតាមបច្ចេកវិទ្យាសម័យទំនើប ចេះច្នៃប្រឌិត ស្គាល់គុណតម្លៃក្នុងការបង្កើនជីវភាពបុគ្គល គ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិ។ ស្ថានភាពបែបនេះហើយដែលទាមទារឱ្យមនុស្សម្នាក់ៗត្រូវតែធ្វើការអភិវឌ្ឍគុណវុឌ្ឍិ ជំនាញតាំងពីក្មេងរហូតដល់ចាស់ មានន័យថា ពលរដ្ឋម្នាក់ៗក្នុងសង្គមត្រូវតែធ្វើការសិក្សាពេញមួយជីវិត ហើយក្រសួងអប់រំ យុវជន និងកីឡាត្រូវតែបង្កលទ្ធភាពគ្រប់បែបយ៉ាងដល់គ្រប់ក្រុមមុខសញ្ញាឱ្យទទួលបានការសិក្សាពេញមួយជីវិត ។

កន្លងទៅ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តតាមគោលនយោបាយអប់រំក្រៅប្រព័ន្ធតាំងតែពីឆ្នាំ២០០២មកម្ល៉េះ ប៉ុន្តែគោលនយោបាយនេះនៅមានចំណុចខ្វះខាតមួយចំនួន ដែលទាមទារឱ្យយើងទាំងអស់គ្នាធ្វើការពិនិត្យឡើងវិញ។ ជាមួយនេះដែរ គោលនយោបាយអប់រំក្រៅប្រព័ន្ធតែមួយមុខ ក៏មិនអាចឆ្លើយតបទៅនឹងបរិបទប្រទេស ក៏ដូចជាបរិបទពិភពលោកដែលកំពុងកែលំអឆ្ពោះទៅរកការអប់រំប្រកបដោយចីរភាព ដោយធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតទាំងអស់គ្នាបានទ្បើយ។

ដូចនេះ ទាមទារឱ្យយើងពិនិត្យឡើងវិញ និងរៀបចំជាគោលនយោបាយសិក្សាពេញមួយជីវិត ដោយមានការរៀបចំផែនការ យុទ្ធសាស្ត្រ រួមជាមួយការកែលំអកម្មវិធី និងសកម្មភាពដែលមានស្រាប់ឱ្យកាន់តែប្រសើរឡើង។ កិច្ចប្រជុំថ្ងៃនេះពិតជាមានសារៈសំខាន់ណាស់ ដែលផ្តល់ឱកាសឱ្យយើងជាអ្នកអនុវត្ត និងអ្នកពាក់ព័ន្ធទាំងអស់ជួបពិភាក្សាគ្នា រិះរកគន្លឹះ និងវិធានការសំខាន់ៗដែលជាធាតុចូលដើម្បីរៀបចំគោលនយោបាយសិក្សាពេញមួយជីវិតសម្រាប់ប្រទេសកម្ពុជា ។

ជាថ្មីម្តងទៀតតាងនាមក្រសួងអប់រំ យុវជន និងកីឡា និងតាងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះគណៈកម្មការរៀបចំកិច្ចប្រជុំ ឯកឧត្តម លោក លោកស្រីជាភ្ញៀវជាតិ អន្តរជាតិ លោក លោកស្រីតំណាងក្រសួងពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍន៍ ដែលបានចូលរួម ផ្តល់នូវទស្សនៈ មតិយោបល់ និងចែករំលែកបទពិសោធន៍លើការងារអប់រំគ្រប់រូបភាព ជាពិសេស SEAMEO CELLL ដែលបានជួយគាំទ្រផ្នែកថវិកា និងបច្ចេកទេស ព្រមទាំងមានកិច្ចសហការគាំទ្រយ៉ាងល្អ ពីអង្គការ UNESCO និង DVV International ដើម្បីឈានទៅសម្រេចនូវយន្តការសហការ ភាពជាដៃគូ ក្រោមគោលដៅ និងយុទ្ធសាស្ត្ររួមគ្នា តាមរយៈការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។

ជាទីបញ្ចប់ ខ្ញុំសូមឱ្យកិច្ចប្រជុំនេះដំណើរការប្រកបដោយជោគជ័យ និងប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ សមាជិក សមាជិកានៃអង្គពិធីទាំងមូល សូមសមប្រកបនូវពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ក្នុងស្មារតីនេះ ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំស្តីពីដំណើរឆ្ពោះទៅអភិវឌ្ឍគោលនយោបាយសិក្សាពេញមួយជីវិត ចាប់ពីពេលនេះតទៅ !**

**សូមអរគុណ !**